**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/៣៨០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៨១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធការគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

ត្រូវបានបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស ដែលសរសេរជាអក្សរកាត់ថា **វ.ជ.អ.ព.** ហើយដែលសរសេរជាភាសាអង់គ្លេសថា National Institute for Special Education និងជាអក្សរកាត់ថា N.I.S.E.។

**វ.ជ.អ.ព.** ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**វ.ជ.អ.ព.** មានទីតាំងបច្ចុប្បន្នស្ថិតនៅដីឡូលេខ៨៥៩ ផ្លូវភ្នំពេញហាណូយ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**ជំពូកទី២**

**តួនាទីនិងភារកិច្ច**

**មាត្រា២ .-**

**វ.ជ.អ.ព.** មានតួនាទីជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡាលើការបណ្តុះបណ្តាលនិងវិក្រឹតការក្របខណ្ឌគ្រូបង្រៀនសម្រាប់បង្រៀនសិស្ស និស្សិតពិការ និងមានភារកិច្ចដូចតទៅ៖

- បណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតសិក្សាសម្រាប់ជនពិការ
- វិក្រឹតការបុគ្គលិកអប់រំគ្រប់កម្រិតសិក្សាសម្រាប់ជនពិការ
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំលើការងារអប់រំជនពិការ
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការឱ្យស្របតាមស្តង់ដាសមត្ថភាពកម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារសម្រាប់ជនពិការ
- បណ្តុះបណ្តាលវិជ្ជាជីវៈបុគ្គលិកអប់រំក្នុងវិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការងារបណ្តុះបណ្តាលនិងវិក្រឹតការបុគ្គលិកអប់រំសម្រាប់ជនពិការ
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍសញ្ញាណថ្មី ផ្នែកភាសា សញ្ញាខ្មែរ ឧបករណ៍ជំនួយ និងសម្ភារៈឧបទេសនានាសម្រាប់អប់រំជនពិការ
- កសាងបណ្តាញកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិដើម្បីធានាគុណភាពបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ជនពិការ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំពិសេសរយៈពេលខ្លី មធ្យម និងវែង
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការវិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន កម្មករ គរុសិស្ស គរុនិស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន

- គៀរគរធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រការបណ្តុះបណ្តាលនិងការស្រាវជ្រាវអប់រំជនពិការ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

**ទ.ជ.អ.ព.** ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការក្របខណ្ឌគ្រូបង្រៀន តាមប្រព័ន្ធ ១២+៤ ដោយអនុលោមតាមក្របខណ្ឌគុណវុឌ្ឍជាតិ។

យន្តការ នីតិវិធី និងកម្មវិធីនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

**ទ.ជ.អ.ព.** ត្រូវដឹកនាំដោយនាយក១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាននិងនាយករងច្រើនបំផុត៥(ប្រាំ)រូប ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ទ.ជ.អ.ព.** មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់និងការិយាល័យចំណុះវិទ្យាស្ថានជាតិអប់រំពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

**ទ.ជ.អ.ព.** ត្រូវមានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលឱ្យស្របតាមគោលនយោបាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងកម្មវិធីសិក្សារបស់វិទ្យាស្ថាន។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

**ទ.ជ.អ.ព.** មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៧ .-**

គរុសិស្ស គរុនិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្រវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់ជនពិការតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយវិទ្យាស្ថានជាតិអប់រំពិសេស ផ្អែកលើបញ្ជីឈ្មោះគរុសិស្ស គរុនិស្សិតដែលបានបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨ .-**

ការចំណាយសម្រាប់ដំណើរការរបស់វិទ្យាស្ថានជាតិអប់រំពិសេស ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ទ.ជ.អ.ព.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធានដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ